# ពិធីការផលិតកម្មតន្ត្រី, ភាពយន្ត និងទូរទស្សន៍: ឧបសម្ព័ន្ធ R

## មានប្រសិទ្ធភាព ចាប់ពីថ្ងៃសុក្រ ទី ១២ ខែមិថុនា ឆ្នាំ ២០២០

តំរូវការនានាខាងក្រោមនេះ មានលក្ខណៈជាក់លាក់ចំពោះផលិតកម្មតន្ត្រី, ខ្សែភាពយន្ត, និងទូរទស្សន៍ ឥឡូវនេះត្រូវបានអនុញ្ញាតិឱ្យបើកឡើងវិញ។ ពិធីការផលិតកម្មតន្ត្រី, ខ្សែភាពយន្ត និងទូរទស្សន៍ ត្រូវតែមានការអនុម័តពីព្រឹត្តិការណ៍ពិសេស និងការថតខ្សែភាពយន្តពិសេសឡុងប៊ិច, នាយកដ្ឋានពន្លត់អគ្គីភ័យ, និងមន្ទីរសុខាភិបាល មុនពេលចេញលិខិតអនុញ្ញាតិ និងប្រតិបត្តិការ។ វិធានការណ៍បន្ថែម ដើម្បីដោះស្រាយលក្ខ័ណ្ឌជាក់លាក់ ចំពោះទីតាំង/ប្រតិបត្តិការ អាចត្រូវបានទាមទារ ឬមានតំរូវការដោយទីក្រុង។ យ៉ាងហោចណាស់, ផលិតកម្មត្រូវបានតម្រូវឱ្យគោរពតាមពិធីការនានា នៅក្នុងឧបសម្ព័ន្ធនេះ។

សូមកត់សំគាល់៖ ឯកសារនេះអាចត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលដែលព័ត៌មាន និងធនធាននានាបន្ថែមទៀត អាចរកបាន ដូច្នេះត្រូវប្រាកដថា នឹងពិនិត្យមើលលើគេហទំព័រឡុងប៊ិច COVID-19 នៅឯ www.longbeach.gov/covid19 ជាប្រចាំ ដើម្បីទទួលបានព័ត៌មានថ្មីៗ ចំពោះឯកសារនេះ។

បញ្ជីផ្ទៀងផ្ទាត់នេះ រួមមាននូវ៖

(1) គោលនយោបាយនានា និងការអនុវត្តនៅកន្លែងធ្វើការ ដើម្បីការពារសុខភាពនិយោជិក
(2) វិធានការណ៍នានា ដើម្បីធានាបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា
(3) វិធានការណ៍នានា ដើម្បីធានាការគ្រប់គ្រងការឆ្លង
(4) ការប្រាស្រ័យទាក់ទងជាមួយនិយោជិក និងសាធារណៈជន
(5) វិធានការណ៍នានា ដើម្បីធានាបាននូវការទទួលបាននូវសេវាកម្មចាំបាច់ ប្រកបដោយសមធម៌

ផ្នែកសំខាន់ៗទាំងប្រាំនេះ ត្រូវតែបានដោះស្រាយខណៈពេលដែលកន្លែងរបស់អ្នក អភិវឌ្ឍនូវពិធីការបើកឡើងវិញនោះ។

**អាជីវកម្មទាំងអស់ ដែលបានស្ថិតនៅក្នុងវិធានការណ៍ណែនាំខាងក្រោមនេះ ត្រូវត្រៀមជាស្រេច ដើម្បីពន្យល់ ថាតើហេតុអ្វីបានជាវិធានការណ៍ណាមួយ ដែលមិនបានត្រូវអនុវត្ត គឺមិនអាចអនុវត្តបាន ចំពោះអាជីវកម្មនេះ។**

ឈ្មោះអាជីវកម្ម: ______________________

អាស័យដ្ឋានកន្លែង: ______________________

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីមែល: CETASKFORCE@LONGBEACH.GOV**

## ការរកទីតាំង ឬស្វែងយល់ទីតាំង

- ❑ អ្នកគ្រប់គ្រងទីតាំង/ជំនួយការ ត្រូវតំរូវអោយមានការបិទបាំងមុខពេលកំពុងរុករក ឬសិក្សាស្វែងយល់ទីតាំង។
- ❑ នៅពេលដែលអាចធ្វើទៅបាន, ក្រុមទីតាំងគួរតែស្វែងរកជម្រើសជំនួសការរុករកដោយផ្ទាល់, ដូចជាជម្រើសនិម្មិត, រូបថត និងរុករកតាមឌីជីថល។
- ❑ បច្ចេកទេសនិងនាយកក្រុមរុករក ត្រូវរៀបចំធ្វើជាក្រុមតូចៗ នៅពេលដែលអាចធ្វើទៅបាន។ ផលិតកម្ម ត្រូវផ្តល់ប្រឹក្សាដល់ការិយាល័យភាពយន្ត នៅពេលដែលមានអ្នកជំនាញខាងបច្ចេកវិទ្យា/អ្នកដឹកនាំរឿង ត្រូវធ្វើឡើង។

## ការថត - ទីតាំងឯកជន/ទីតាំងសាធារណៈ

- ❑ លិខិតអនុញ្ញាតិខ្សែភាពយន្ត នឹងត្រូវបានអនុញ្ញាតិ ដោយផ្អែកលើករណីនីមួយៗ។ ទំហំតួសំដែង/សមាជិកក្រុម នឹងត្រូវរក្សាទុកជាអប្បបរមា ហើយនឹងត្រូវបានកំណត់ដោយទំហំទីតាំង និងទំហំផលិតកម្ម។
- ❑ ជំរុំមូលដ្ឋាន និងកន្លែងចតយានយន្តរបស់ក្រុម បានត្រូវបិទចំពោះសាធារណៈជន។
- ❑ ផលិតកម្ម និងផ្តល់សន្តិសុខ ដើម្បីការពារការចូលរបស់សាធារណៈជន។
- ❑ ឈុតឆាកផលិតកម្ម បានត្រូវបិទចំពោះសាធារណៈជន។
- ❑ ផលិតកម្ម នឹងផ្តល់សន្តិសុខ និង/ឬទីក្រុងអាចតម្រូវឱ្យមានបុគ្គលិកទីក្រុង ដើម្បីធានាថាឈុតឆាកនេះ គឺមិនអាចចូល បានសម្រាប់សាធារណៈជននោះទេ។
- ❑ ផលិតកម្ម នឹងគ្រប់គ្រងការត្រួតពិនិត្យសីតុណ្ហភាព និង/ឬការត្រួតពិនិត្យរោគសញ្ញា លើតួសំដែង/សមាជិកក្រុមទាំងអស់ នៅពេលចុះឈ្មោះចូល (ត្រួតពិនិត្យសីតុណ្ហភាព និង/ឬត្រួតពិនិត្យរោគសញ្ញា ត្រូវតែជាផ្នែកមួយនៃពិធីការរបស់ផលិតកម្ម ដែលត្រូវបានអនុវត្ត និងបញ្ជូនទៅកាន់ទីក្រុង)។
- ❑ នៅពេលដែលចម្ងាយប្រាំមួយ (៦) ហ្វីត មិនអាចរក្សាបាន (មានការលើកលែងចំពោះទេពកោសល្យ និងតួសំដែង ក្នុងកំឡុងពេលថតតែប៉ុណ្ណោះ)។ សមាជិកក្រុម/តួទាំងអស់ ដែលមានទំនាក់ទំនងជាមួយសមាជិកក្រុម/តួផ្សេងទៀត ក្នុងអំឡុងវេនរបស់ពួកគេ ត្រូវបានផ្តល់ជូន, ដោយមិនគិតថ្លៃ, នូវគម្របមុខក្រណាត់មួយ។ គម្របនេះ ត្រូវពាក់ដោយសមាជិកក្រុម/តួសំដែងគ្រប់ពេលវេលាទាំងអស់ នៅពេលថ្ងៃធ្វើការ នៅពេលមានទំនាក់ទំនង ឬទំនងជានឹងមកទាក់ទង/ប៉ះពាល់ជាមួយអ្នកដទៃ។ សមាជិកក្រុម/តួសម្តែង មិនត្រូវពាក់គម្របមុខទេ ពេលនៅម្នាក់ឯង។
- ❑ ផលិតកម្ម ត្រូវមានស្ថានីយ៍អនាម័យ/លាងសម្អាតដៃ គ្រប់គ្រាន់។ ផលិតកម្ម ត្រូវមានតំរូវការរក្សាការឃ្លាតឆ្ងាយរាងកាយពី

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

គ្នា នៅទីកន្លែងណាដែលអាចធ្វើទៅបាន។

- ❑ ការគ្រប់គ្រងអាហារ (សេវាកម្មរៀបចំម្ហូបអាហារ/អាជីវៈ ឬបររកស៊ី) តម្រូវឱ្យអនុវត្តតាម ពិធីសារអ្នកលក់ចំណីអាហារចល័ត (ឧបសម្ព័ន្ធ ៗ) ។

## ការថត - លំនៅដ្ឋាន

- ❑ ការថតតាមគេហដ្ឋាន នឹងត្រូវបានអនុញ្ញាតិ ដោយផ្អែកលើករណីនីមួយៗ។ ទំហំតួសំដែង/សមាជិកក្រុម នឹងត្រូវរក្សាទុកជាអប្បបរមា ហើយនឹងត្រូវបានកំណត់ដោយទំហំអចលនទ្រព្យ, ការរៀបឆាក, ដង់ស៊ីតេ និងភាពជិតទៅនឹងអ្នកជិតខាង និងទំហំផលិតកម្ម។
- ❑ បិទផ្លាក ហាមចត នៅក្នុងតំបន់លំនៅដ្ឋាន នឹងត្រូវបានអនុញ្ញាតិអោយបិទនៅមុខទ្រព្យសម្បត្តិទីតាំង តែប៉ុណ្ណោះ។
- ❑ ជំរុំមូលដ្ឋាន និងកន្លែងចតរបស់ក្រុម នឹងត្រូវបិទចំពោះសាធារណៈជន និងមានទីតាំងនៅខាងក្រៅសង្កាត់អ្នកស្រុក។
  - ○ ផលិតកម្ម នឹងផ្តល់សន្តិសុខ ដើម្បីការពារការចូលរបស់សាធារណៈជន។
- ❑ ឈុតឆាកផលិតកម្ម ត្រូវបានបិទចំពោះសាធារណៈជន។
  - ○ ផលិតកម្ម នឹងផ្តល់សន្តិសុខ និង/ឬទីក្រុងអាចតម្រូវឱ្យមានបុគ្គលិកទីក្រុង ដើម្បីធានាថាឈុតឆាកនេះ គឺមិនអាចចូល បានសម្រាប់សាធារណៈជននោះទេ។
- ❑ ផលិតកម្ម នឹងគ្រប់គ្រងការត្រួតពិនិត្យសីតុណ្ហភាព និង/ឬការត្រួតពិនិត្យរោគសញ្ញា លើតួសំដែង/សមាជិកក្រុមទាំងអស់ នៅពេលចុះឈ្មោះចូល (ត្រួតពិនិត្យសីតុណ្ហភាព ត្រូវតែជាផ្នែកមួយ នៃផែនការសុវត្ថិភាព/អនាម័យ)។
- ❑ មានតំរូវការអោយបិទបាំងគម្របមុខក្រណាត់ចំពោះ តួសំដែង/សមាជិកក្រុមទាំងអស់ នៅពេលពួកគេនៅជុំវិញអ្នកដទៃ ឬនៅពេលដែលចម្ងាយប្រាំមួយ (៦) ហ្វីត មិនអាចរក្សាបាន (មានការលើកលែងចំពោះទេពកោសល្យ និងតួសំដែង ក្នុងកំឡុងពេលថតតែប៉ុណ្ណោះ)។ សមាជិកក្រុម/តួទាំងអស់ ដែលមានទំនាក់ទំនងជាមួយសមាជិកក្រុម/តួផ្សេងទៀត ក្នុងអំឡុងវេនរបស់ពួកគេ ត្រូវបានផ្តល់ជូន, ដោយមិនគិតថ្លៃ, នូវគម្របមុខក្រណាត់មួយ។ គម្របនេះ ត្រូវពាក់ដោយសមាជិកក្រុម/តួសំដែងគ្រប់ពេលវេលាទាំងអស់ នៅពេលថ្ងៃធ្វើការ នៅពេលមានទំនាក់ទំនង ឬទំនងជានឹងមកទាក់ទង/ប៉ះពាល់ជាមួយអ្នកដទៃ។ សមាជិកក្រុម/តួសម្តែង មិនត្រូវពាក់គម្របមុខទេ ពេលនៅម្នាក់ឯង។
- ❑ ផលិតកម្ម ត្រូវមានស្ថានីយ៍អនាម័យ/លាងសម្អាតដៃ គ្រប់គ្រាន់។
- ❑ ផលិតកម្ម ត្រូវមានតំរូវការរក្សាការឃ្លាតឆ្ងាយរាងកាយពីគ្នា នៅទីកន្លែងណាដែលអាចធ្វើទៅបាន។
- ❑ ការគ្រប់គ្រងអាហារ (សេវាកម្មរៀបចំម្ហូបអាហារ/អាជីវៈ ឬបររកស៊ី) តម្រូវឱ្យអនុវត្តតាម ពិធីសារអ្នកលក់ចំណីអាហារចល័ត (ឧបសម្ព័ន្ធ ៗ) ។

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីមែល: CETASKFORCE@LONGBEACH.GOV**

## ការថត - លើឆាក

- ❑ ស្លាកសញ្ញាដែលបញ្ជាក់ថា អោយពាក់គម្របមុខ ហើយដៃត្រូវតែលាងសម្អាត/ធ្វើអនាម័យ ឱ្យបានញឹកញាប់។
- ❑ ចំងាយរាងកាយឃ្លាតពីគ្នា ៦ ហ្វីត (នៅកន្លែងណាដែលអាចធ្វើទៅបាន)។
- ❑ ឈុតឆាក ត្រូវបានបិទចំពោះសាធារណៈជន និង/ឬ តួសំដែង/សមាជិកក្រុម ដែលមិនចាំបាច់។

## តំរូវអោយមានផែនការសុវត្ថិភាព/អនាម័យ នៅគ្រប់ទីតាំងទាំងអស់

- ❑ ត្រួតពិនិត្យរោគសញ្ញា និង/ឬសីតុណ្ហភាព ដែលនឹងត្រូវបានគ្រប់គ្រងដោយផលិតកម្ម នៅពេលឆែកឆេ ឬចុះឈ្មោះចូល។
- ❑ ត្រូវតែរៀបចំអោយមាន នូវកន្លែងលាងដៃមានទឹកដែលកំពុងដំណើរការ, សាប៊ូ និងក្រដាស់អនាម័យ (អាចចែកចាយអោយដោយប្រើប្រព័ន្ធមិនប៉ះពាល់, នៅកន្លែងណាដែលអាចធ្វើទៅបាន) ។
- ❑ ឧបករណ៍កន្លែងលាងដៃ/អនាម័យ ត្រូវរក្សាឱ្យស្អាត និងមានស្តុកទុកអោយបានល្អ។
- ❑ ស្ថានីយ៍ត្រដុះដៃដែលមានមូលដ្ឋានជាតិអាល់កុល ("ប្រដាប់ធ្វើអនាម័យដៃ") ដែលមានជាតិអាល់កុលយ៉ាងតិច ៦0% ត្រូវដាក់ជាយុទ្ធសាស្ត្រ នៅជុំវិញកន្លែងធ្វើការ និងងាយស្រួលចូលប្រើ, ស្តុកទុក និងថែរក្សា។
- ❑ ផ្ទៃដែលមានការប៉ះពាល់ខ្ពស់ នឹងត្រូវសំអាតចោល អោយបានយ៉ាងញឹកញាប់។
- ❑ ផលិតកម្មនឹងធ្វើឱ្យទីតាំងមានអនាម័យនៅពេលរុំ ដោយប្រើវិធីសាស្ត្រ និងគ្រឿងផ្គត់ផ្គង់រំងាប់មេរោគ ដែលបានចុះបញ្ជីដោយ EPA ជាមួយនឹងការអះអាងប្រឆាំងនឹងជំងឺ SARS-CoV-2។

**វិធានការណ៍បន្ថែមណាមួយ ដែលមិនបានដាក់បញ្ចូលខាងលើ គួរតែត្រូវបានដាក់រាយនៅលើទំព័រដាច់ដោយឡែក, ដែលអាជីវកម្ម គួរតែភ្ជាប់ជាមួយនឹងឯកសារនេះ។**

**អ្នកអាចទាក់ទងមនុស្សខាងក្រោមនេះ បើសិនជាអ្នកមានសំណួរ ឬយោបល់នានា អំពីពិធីការនេះ:**

ឈ្មោះទំនាក់ទំនងអាជីវកម្ម: ______________________

លេខទូរស័ព្ទ: ______________________

កាលបរិច្ឆេទកែប្រែចុងក្រោយ: ______________________

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**